# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

The Electoral Reform Alliance (ERA)

ភ្នំពេញថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤

## សេចក្តីប្រកាសព័ត៌មានស្តីពី
## ដំណើរការកំណែទម្រង់ការបោះឆ្នោត

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតសូមសម្តែងការសោកស្តាយចំពោះកិច្ចប្រជុំនៃគណៈកម្មការចម្រុះរបស់គណបក្សទាំងពីរ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ដែលមិនអាចឈានទៅដល់ការព្រមព្រៀងដើម្បីចេញលទ្ធផលជាក់លាក់ ។

គណៈកម្មការនេះត្រូវតែរៀបចំផែនការសកម្មភាពនៃកំណែទម្រង់ការបោះឆ្នោតដោយកំណត់អំពីពេលវេលាអោយបានច្បាស់លាស់។

គណៈកម្មការចម្រុះនេះត្រូវបង្កើតអនុគណៈកម្មការបច្ចេកទេសផ្សេងៗគ្នាដើម្បីចាប់ផ្តើមធ្វើការ និងជជែកលម្អិតទៅលើ៖

១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២ ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត

៣ ប្រព័ន្ធផ្សព្វផ្សាយ

៤ យន្តការដោះស្រាយវិវាទនៃការបោះឆ្នោត

៥ ការរៀបចំបង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុនយោបាយ

គណៈកម្មការចម្រុះនេះ ត្រូវតែធ្វើការប្រជុំអោយបានញឹកញាប់ជាងនេះ ដើម្បីបង្ហាញអោយឃើញពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាជាតិយ៉ាងពិតប្រាកដ។

គណៈកម្មការចម្រុះនេះ ត្រូវធ្វើការពិភាក្សាដោយផ្តោតទៅលើប្រធានបទ នៃកំណែទម្រង់ការបោះឆ្នោតដែលថ្នាក់ដឹកនាំកំពូលនៃគណៈបក្សទាំងពីរបានឯកភាពកាលពីថ្ងៃទី១៦ កញ្ញា ឆ្នាំ២០១៣ ជាជាងបញ្ហាដទៃទៀត។

សម្រាប់ព័ត៌មានបន្ថែម៖

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោក នី ចរិយា | អាដហុក | ០១១២៧៤៩៥៩ |
| • អ្នកស្រី រស់ សុភាព | ហ្គាដស៊ី | ០១២៦២៨៧៥៧ |
| • លោក ព្រាប កុល | តម្លាភាពកម្ពុជា | ០១២៨៧៧៨៣៣ |
| • លោក ហង្ស ពុទ្ធា | និចហ្វិច | ០១២៩៥៩៦៦៦ |
| • លោក យង់ គិមអេង | ភីដីភី សិនធ័រ | ០១៦៨២៨២១១ |
| • លោក គល់ បញ្ញា | ខុមហ្វ្រែល | ០១២៩៤២០១៧ |
| • លោក សុខ ពិទូរ្យ | វាយ ស៊ី ស៊ី | ០១៧២៧៣៣០៣ |
| • លោក គាន ពន្លក | ជ្រាក | ០១២៥៥១៤៦៦ |
| • លោក ហុង គីមសួន | សម្ព័ន្ធស៊ីសា | ០១២៩៤៥៥០៥ |
| • លោក ប៉ា ងួនទៀង | ស៊ី ស៊ី អាយ អឹម | ០៦០៤០៩៩ ៩៩ |
| • លោក យ៉េង វិរៈ | ខ្លេក | ០១២៨០១២៣៥ |